# របាយការណ៍ប្រចាំឆ្នាំ ២០១១

# ការអនុវត្តគំរោង ទប់ស្កាត់ការរីករាលដាលនៃជម្ងឺអេដស៍កាមរោគ ក្នុងចំណោមស្ត្រីធ្វើការកន្លែងសេវាកំសាន្ត និងអតិថិជន

## ( គំរោងស្មាតហ្គើល )




Strategy 4: Capacity Building

Strategy 3: Mobilizing stakeholders

Strategy 2: Access to health information, products and services

Strategy 1: Emphasize risk reduction and promote safer sexual practices





**Funding Source**:

- USAID

**Human Resources**:

- 44 staff
- 86 SMARTgirl Leaders/Volunteers

Smart Girl | Casino Worker | You're THE MAN! | DU/IDU

## I. សេចក្តីផ្តើម

សមាគមនារីដើម្បីសន្តិភាព និងការអភិវឌ្ឍន៍ ជាអង្គការមិនរកប្រាក់ចំណេញដែលធ្វើការលើកកម្ពស់ស្ថានភាពស្ត្រីក្នុងប្រទេសកម្ពុជា។ សមាគមនារីដើម្បីសន្តិភាពនិងការអភិវឌ្ឍន៍(CWPD) បានប្តូរឈ្មោះពីសមាគមនារីកម្ពុជា ដែលបានកកើតឡើងក្នុងថ្ងៃទី ២ ធ្នូ ឆ្នាំ១៩៧៨ ជាស្ថាប័នរបស់ជាតិ ។ ឆ្នាំ ២០០០ បានបន្តចុះជាអង្គការមិនមែនរដ្ឋាភិបាលក្នុងក្រសួងមហាផ្ទៃ ។

**ទស្សនៈវិស័យ:** ប្រជាជនកម្ពុជារស់នៅប្រកបដោយ សុភមង្គល យុត្តិធម៌ សន្តិភាព អភិវឌ្ឍន៍ និងការគោរពសិទ្ធស្មើភាពរវាងបុរសនិងស្ត្រី ។

បេសកកម្ម: **លើកកម្ពស់ស្ថានភាពស្ត្រីនៅក្នុងប្រទេសកម្ពុជា ដោយបង្កើនការជឿទុកចិត្តលើសមត្ថភាពខ្លួនឯងដើម្បីក្លាយជាអ្នកដឹកនាំ ដែលមានភាពម្ចាស់ការ និងមានសិទ្ធិទទួលបាន ដោយសមធម៌នូវធនធាន និងផលប្រយោជន៍ពីគ្រប់ការចូលរួមយ៉ាងសកម្មក្នុងសកម្មភាព សង្គម វប្បធម៌ សេដ្ឋកិច្ច និងនយោបាយនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិ ។**

សមាគមនារីមានសាខាប្រតិបត្តិ២៤ខេត្ត និង រាជធានី ក្នុងឆ្នាំសារពើព័ន្ធគំរោង២០១១ មានគំរោងចំនួន៨គ្របដណ្តប់ក្នុង១៦ខេត្តនិងរាជធានីក្នុងនោះមាន រាជធានីភ្នំពេញ ខេត្តកណ្តាល តាកែវ កំពត កំពង់ស្ពឺ កោះកុង បាត់ដំបង សៀមរាប ព្រះវិហារ ក្រចេះ ស្ទឹងត្រែង កំពង់ឆ្នាំង កំពង់ធំ កំពង់ចាម មណ្ឌលគិរី និងប៉ៃលិន។

សំរាប់ឆ្នាំ២០១១ CWPD មានថវិកាចំនួន ៨៧២,៦៨៥ដុល្លារសហរដ្ឋអាមេរិក ពីម្ចាស់ជំនួយដូចជា DCA EU Oxfam Norvib HBF, LEVI STRAUSS FOUNDATION, SODI (Germany), GFATM-R7, USAID (PRASIT), USAID (PSI) តាមរយៈមូលនិធិទាំងនេះមាន ៦៥.៣១% ជាកម្មវិធីបង្ការនិងការពារមេរោគអេដស៍ ១៤.៧៥% លើកម្មវិធីអភិវឌ្ឍន៍សហគមន៍(ទឹកស្អាត អនាម័យ អប់រំ) ១០.៥៦% លើកកម្មវិធីសុខភាពបន្តពូជ ផែនការគ្រួសារ ២.៦%លើសុខភាពកុមារ និង ៦.៧៨% លើកម្មវិធីលើកកំពស់ស្ត្រីចូលរួមក្នុងវិស័យនយោបាយ។

ចាប់ពីខែ តុលា ២០០៧ តាមរយៈគំរោងប្រសិទ្ធិ ឧបត្ថម្ភដោយអង្គការFHI 360 CWPDបានអនុវត្តគំរោង បង្ការនិងការពារមេរោគអេដស៍និងការអប់រំសុខភាពផ្លូវភេទ សំរាប់ស្ត្រីធ្វើការក្នុងសេវាកំសាន្ត និងអតិថិជនបុរស ជាមួយខ្ទង់ថវិកាចំនួន ៩១១,៣៣៦ដុល្លារសហរដ្ឋអាមេរិក ក្នុងតំបន់គោលដៅរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង បាត់ដំបង សៀមរាប និង ប៉ៃលិន។ ក្រុមគោលដៅក្នុងឆ្នាំ២០១១ មានស្ត្រីធ្វើការក្នុងសេវាកំសាន្តចំនួន ៧,៥៣៧នាក់ បុរសជាអតិថិជនចំនួន ៥៧,៥៤១នាក់ បុគ្គលិកាសុីណូ ២,១៧៣នាក់ អ្នកប្រើប្រាស់ គ្រឿងញៀនចំនួន ៤០៩នាក់។

## II. ការពិពណ៌នាអំពីគំរោង

### A. ប្រវត្តិ និងទីតាំង ក្រុមគោលដៅ

## 1 ខេត្ត ស្រុក គ្របដណ្តប់ដោយគំរោង

ចាំតាំងពីចាប់ផ្តើមគំរោង **ប្រសិទ្ធ** ដែលឧបត្ថម្ភដោយជំនួយសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ(USAID)មក CWPD បានអនុវត្តកម្មវិធីបង្ការ និងការពារ មេរោគអេដស៍ និងការអប់រំផ្នែកសុខភាពផ្លូវភេទ ក្នុងចំណោមស្ត្រីធ្វើការសេវាកំសាន្ត និងបុរសជាអតិថិជន ក្នុងរាជធានីភ្នំពេញ (ខណ្ឌដូនពេញ, ចំការមន,ឫស្សីកែវ, មានជ័យ) កំពង់ស្ពឺ (ក្រុងច្បារមន, ភ្នំស្រុក និង ស្រុកឧដុង្គ) កំពង់ឆ្នាំង (ក្រុងកំពង់ឆ្នាំង, បរិបូរណ៍, រលាប្អៀរ និង ស្រុកកំពង់ត្រលាច) បាត់ដំបង (ក្រុងបាត់ដំបង សង្កែ និងស្រុកមោងឫស្សី) សៀមរាប (ក្រុងសៀមរាប) និង ប៉ៃលិន (សាលាក្រៅ និងក្រុងប៉ៃលិន ) កណ្តាល ( ក្រុងតាខ្មៅ និង ស្រុកកៀនស្វាយ) និង មានផ្នែកឯកជន ២ទៀតគឺ កម្មវិធីក្នុងកាស៊ីណូក្នុងកាស៊ីណូ ភ្នំពេញ ណាហ្គាហ្វើល , ខេត្តប៉ៃលិន ម្កុដពេជ្រ, វិចតូរីយ៉ា, ស៊ីសា និងស៊ីណូប៉ៃលិន។

## 2 ស្ត្រីធ្វើការសេវាកំសាន្ត និងបុគ្គលិកកាស៊ីណូក្នុងតំបន់គោលដៅ

តាមរយៈគំរោងប្រសិទ្ធិ CWPD ធ្វើផែនទី សំរាប់បានគោលដៅក្នុងចំណោម ក្រុមប្រជាសាស្ត្រដូចខាងក្រោម:

ក្នុងរាជធានីភ្នំពេញ ស្ត្រីធ្វើការក្នុងសេវាកំសាន្តសរុប ១៨,៣០១នាក់ ក្នុងផែនទីរបស់ CWPD មាន១,៨០០នាក់ ជាសមិទ្ធិផលសំរេចបានមានស្ត្រីចំនួន ២១២៩នាក់ ទទួលបានការអប់រំផ្សព្វផ្សាយពីក្រុមការងារគំរោង។ ក្នុងកាស៊ីណូ ណាហ្គាហ្វើល CWPD មានបុគ្គលិកប្រមាណចំនួន៤០០០ នាក់ ក្នុងនោះក្រុមការងារបានអប់រំផ្សព្វផ្សាយដល់បុគ្គលិកស្រី ចំនួន ១២២៩ នាក់ ខេត្តកំពង់ស្ពឺ មានស្ត្រីក្រុមគោលដៅរួមចំនួន ៧៣២ អប់រំផ្សព្វផ្សាយបានចំនួន ៨៧៨នាក់ ខេត្តកំពង់ឆ្នាំងស្ត្រីមានចំនួន៨៧២នាក់ ប៉ុន្តែការអប់រំផ្សព្វផ្សាយបានចំនួន៨៩៩នាក់ (លើសពីចំនួនស្ត្រីក្នុងគោលដៅដោយមានអ្នកថ្មីៗ)។ ខេត្តបាត់ដំបងចំនួនស្ត្រីសរុបខេត្តចំនួន១៦៦៩នាក់ក្នុងនោះ CWPD កំណត់ចំនួនអប់រំ ១៣០០នាក់ អប់រំបាន១១២១នាក់ ខេត្តសៀមរាបសរុបចំនួនស្ត្រីធ្វើការក្នុងសេវាកំសាន្ត មានចំនួន ៣៦៩០នាក់ CWPD កំណត់ចំនួនអប់រំ ១៦០០ អប់រំបាន ១៩០០នាក់ ក្នុងខេត្តប៉ៃលិន ស្ត្រីក្នុងការធ្វើផែនទីរបស់ CWPD មានចំនួន ៤២៤ អប់រំបានចំនួន៤៣១នាក់ ចំណែកកាស៊ីណូប៉ៃលិនមានស្ត្រីក្នុងផែនទីចំនួន៩៥០នាក់ ជាលទ្ធផលសំរេចបានការអប់រំចំនួន៩៤៦នាក់ ។ ក្នុងខេត្តកណ្តាលមានស្ត្រីសរុបចំនួន ១៤៩១នាក់ CWPD កំណត់ចំនួនអប់រំ ៧០០ អប់រំបាន ៩២៩នាក់។

## 3 ក្រុមងាយរងគ្រោះក្នុងចំណោមក្រុមគោលដៅ

### a. ស្ត្រីធ្វើការសេវាកំសាន្ត និង បុរសជាអតិថិជន

ថ្វីបើទទួលបានជោគជ័យ **100%** ក្នុងការប្រើប្រាស់ស្រោមអនាម័យ ក្នុងការកាត់បន្ថយអត្រា ប្រេវ៉ា ឡង់មេរោគអេដស៍ ចំណោម ស្ត្រីធ្វើការសេវាកំសាន្ត តែដោយមានការផ្លាស់ប្តូរបរិបទ សេដ្ឋកិច្ចសង្គម ទាមទារអោយមានវិធីសាស្ត្រថ្មីៗសំរាប់ធ្វើអោយប្រសើរ

ឡើងនូវសុខភាពក្នុងចំណោម ក្រុមងាយរងគ្រោះ។ ខណៈពេលដែលមានការប៉ាន់ប្រមាណថាមានស្ត្រីច្រើនជាង ២០,០០០នាក់នាពេលបច្ចុប្បន្ន ធ្វើការក្នុងសេវាកំសាន្តក្នុងនោះមានស្ត្រីពី ២,០០០**នាក់** ទៅ ៥,០០០នាក់ តែប៉ុណ្ណោះដែលធ្វើការផ្ទាល់ក្នុងបន (ការបង្ហាញពីចំនួន នៃការចុះថយនេះបញ្ជាក់ពី**ការអនុវត្ត**ច្បាប់ បង្ក្រាបអំពើជួញដូរមនុស្ស)។

ចំពោះអ្នកដែលបន្តធ្វើការ**នៅ**ក្នុងកន្លែងសេវាកំសាន្តផ្សេងៗទៀត ក្រៅពីផ្ទះបនប្រហែលជាមិនលក់ភេទ។ ការប្រើប្រាស់ស្រោមអនាម័យ ១០០% អំឡុងពេលរួមភេទ និង និយាមបែបបទស្តង់ដា សំរាប់ការអប់រំគឺផ្តោតតែលើស្ត្រីធ្វើការនៅផ្ទះបន និងបង្ហាញពីភាពជោគជ័យតិចតួចចំពោះស្ត្រីធ្វើការក្រៅផ្ទះបន។ តាមរយះរបាយការណ៍ក្នុងឆ្នាំ ២០០៧ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ មាន៥០%នៃស្ត្រីនៅផ្ទះបនត្រូវបានគ្របដណ្តប់ រីឯស្ត្រីក្រៅផ្ទះបនបានគ្របដណ្តប់ត្រឹមតែ៨% តែប៉ុណ្ណោះ។ ប្រមាណជា ៥៩% នៃស្ត្រីរកស៊ីនៅផ្ទះបនបានទៅទទួលសេវាជំងឺកាមរោគនៅគ្លីនិករដ្ឋ រឺ គ្លីនិកសុខភាពគ្រួសារចំណែកឯស្ត្រីមិននៅក្នុងផ្ទះបនបានទៅទទួលសេវាត្រឹមតែ១៧%ក្នុងអំឡុងពេលដូចគ្នា ។ វាពិតជាពិបាកក្នុងការជឿជាក់ថាស្រោមអនាម័យ និង ព័ត៌មានស្ត្រីពីសុខភាពផ្លូវភេទអាចបានទទួលដោយស្ត្រីធ្វើការក្នុងគ្រឹះស្ថានកំសាន្តក្រៅពីផ្ទះបន ហើយអង្គការជាដៃគូដែលអនុវត្តន៍គំរោងតែងតែរាយការណ៍ពីការបដិសេធន៍ពីសំណាក់ស្ត្រីនៅទីនោះ។

មិនថាស្ត្រីធ្វើការក្នុងបនរឺសេវាកំសាន្តនានា ពួកគាត់ត្រូវការសេវាសុខភាពផ្លូវភេទជាពិសេសសេវា កាមរោគ និងជម្ងឺអេដស៍។ របាយការណ៍ពីការសិក្សាទាក់ទងនិងជម្ងឺកាមរោគបានបង្ហាញថា ស្ត្រីធ្វើការសេវាកំសាន្តភាគច្រើនជាដៃគូ និងបុរសទ្វេភេទ។ រវាង ១៧% ទៅ ២៦ % នៃ ស្ត្រីធ្វើការសេវា កំសាន្តទទួលការរំលូត ក្នុងឆ្នាំ ២០០៦ **(BSS 2007)** ។ ការប្រើប្រាស់គ្រឿងញៀន ក៏ជាបញ្ហាមួយក្នុងចំ**ណោម** ស្ត្រីធ្វើការសេវាកំសាន្ត ១០% នៃស្ត្រីធ្វើការក្នុងបនរាយការណ៍ថា បានប្រើប្រាស់ ថ្នាំយ៉ាម៉ា**(BSS 2007)** ហើយ ៦% នៃស្ត្រីធ្វើការក្នុងកាស៊ីណូធ្លាប់ចាក់ថ្នាំញៀន **(PSI 2006)**។សំរាប់អ្នកលក់ស្រាបៀរនិងស្ត្រីធ្វើការនៅខារ៉ាអូខេបានរាយការណ៍ថា ជាមធ្យមមានដៃគូ ៤ទៅ ១៥នាក់ក្នុងមួយឆ្នាំ ដែលក្នុងនោះយ៉ាងហោចណាស់មានដៃគូម្នាក់ដែលមិនបានប្រើប្រាស់ស្រោមអនាម័យទៀងទាត់**(BSS 2007)**។

ការខិតខំប្រឹងប្រែងការពារមេរោគអេដស៍ក្នុងចំណោមស្ត្រីធ្វើការសេវាកំសាន្តបានផ្តោតសំខាន់លើការកាត់បន្ថយការប្រឈមមុខផ្ទាល់ខ្លួនរបស់ស្ត្រីក៏ដូចជាបុរសជាដៃគូដោយសំដៅលើការប្រុងប្រយ័ត្ន ចំពោះមេរោគអេដស៍ និងការអប់រំស្ត្រីដូចជាវិធីសាស្ត្រ ចរចារអោយដៃគូប្រើប្រាស់ស្រោមអនាម័យ។ ក្នុងប្រទេសកម្ពុជាបុរស (ជាប្តី សង្សារ ដៃគូទៀងទាត់ និងភ្ញៀវរបស់ស្ត្រី) ជាអ្នកកំណត់ថាតើពេលណា កន្លែងណាត្រូវប្រើស្រោមអនាម័យ។

## b. បុគ្គលិកកាស៊ីណូ

តាំងពីដើមឆ្នាំ ១៩៩០មក កាស៊ីណូត្រូវបានបង្កើតឡើងតាមបណ្តោយព្រំដែនថៃកម្ពុជា និង វៀតណាម កម្ពុជា។ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានហាមប្រាមចំពោះភ្ញៀវជាជនជាតិខ្មែរ។ ក៏ប៉ុន្តែចំពោះជនជាតិផ្សេងទៀតបានឆ្លងដែនមកពីប្រទេសផ្សេង។ អ្នកលេងល្បែងជនជាតិថៃ និងវៀតណាមរាប់រយនាក់បានឆ្លងដែនជារៀងរាល់ថ្ងៃមកលេង

ល្បែង។ បុគ្គលិកកាស៊ីណូរាប់ពាន់នាក់មានទាំងជនជាតិខ្មែរ និងវៀតណាម និងអ្នកចំណាកស្រុកមួយចំនួនទៀតបានទៅធ្វើការនៅទីនោះដោយរំពឹងថាមានជីវិតប្រសើរ។

### c. អ្នកប្រើប្រាស់គ្រឿងញៀន

មានភស្តុតាងជាច្រើនបានបង្ហាញថានៅពេលពួក គេប្រើប្រាស់ គ្រឿងញៀនមានចំណង់ផ្លូវភេទ និងបង្កើនអត្រាឆ្លងជំងឺកាមរោគ និងជំងឺអេដស៍តាមរយៈ អាកប្បកិរិយារបស់ពួកគេ។ ១០%នៃស្ត្រីនៅផ្ទះបនបានអោយដឹងថា បានប្រើប្រាស់ គ្រឿងញៀន យ៉ាម៉ា**(BSS 2007)** ស្ត្រីខារ៉ាអូខេចំនួន ៦%ធ្លាប់ប្រើថ្នាំញៀនប្រភេទចាក់**(PSI** ២០០៦)។ **FHI360** បានសិក្សា ជាមួយស្ត្រីធ្វើការសេវាកំសាន្តចំនួន ៨៤៧នាក់ តាមរយៈ ស្មាតហ្វើលក្លឹប ក្នុងក្រុងភ្នំពេញ កំពង់ចាម សៀមរាប បាត់ដំបង និងប៉ោយប៉ែត ដោយបានរកឃើញថា ២៣% (១៩៦) បានប្រើប្រាស់គ្រឿងញៀន។ក្នុងចំណោមពួកគេ ១.៥% ធ្លាប់ប្រើប្រាស់ហេរ៉ូអ៊ីនជាមួយ អត្រា ០.៥% ប្រើតាមការចាក់។ ចំពោះអត្រាប្រើប្រាស់មេអំហ្វេតាមីនមានដល់ ៧៤.៥% ។

ការអនុវត្តន៍គោលការណ៍ភូមិឃុំមានសុវត្ថិភាពច្បាប់ប្រឆាំងការជួញដូរបានធ្វើអោយមានការផ្លាស់ប្តូរទំរង់នៃសេវាផ្លូវភេទមិនផ្ទាល់។ ស្ត្រីធ្វើការក្នុងសេវាកំសាន្ត ដូចជាកន្លែងម៉ាស្សា ក្លឹប កាស៊ីណូ សណ្ឋាគារ ហាងស្រាបៀរ ក្លឹបស្ទួឃើ និងផ្ទះសំណាក់ អាចត្រូវបានចរចារដើម្បីធ្វើការរួមភេទ។

ដើម្បីសំរបសំរួលអោយការបង្ការមេរោគអេដស៍ និងជំងឺកាមរោគមានប្រសិទ្ធិភាពក្នុងចំណោមអ្នករកស៊ីផ្លូវភេទ និងដៃគូ ត្រូវយល់ច្បាស់ពីបែបបទនៃការឆ្លងថ្មី ហើយត្រូវមានការយល់ដឹងពីអនុសាសន៍ចំបង និងការវិភាគលើការឆ្លើយតបទាក់ទងការការពារ។

## 4 អង្គការជាដៃគូក្នុងតំបន់គោលដៅរួមគ្នាជាមួយCWPD

**រាជធានីភ្នំពេញ:** ខណ្ឌមានជ័យ ចំការមន និងឫស្សីកែវ អង្គការជាដៃគូធ្វើកា រអប់រំដល់ស្ត្រីមាន CWDA, SIT, KWCD CWPD/GFATM-R7 ។ អង្គការដែលផ្តល់សេវាសុខភាពដល់ស្ត្រីមាន KOSHER, ATECT-PSF-GFATM-R5, RHAC ។ ចំពោះដៃគូរដ្ឋមានមណ្ឌលសុខភាពដូនពេញនិងទួលគោកដែលស្ថិតក្នុងប្រតិបត្តិខាងជើង និង មណ្ឌលសុខភាពព្រែកឯង មណ្ឌលសុខភាពក្បាលកោះ។ ចំពោះបុគ្គលិកកាស៊ីណូណាហ្គា ហ្វើលទទួលសេវាសុខភាព ពីមន្ទីរពេទ្យបង្អែកចំការមនក្នុងខណ្ឌចំការមន។ អង្គការដែលផ្តល់សេវាសុខភាពមាន MEC, Chhouksar and ATECT-PSF GFATM-R5, និង WNU ។

**ខេត្តកំពង់ស្ពឺ:** អង្គការដែលមានសកម្មភាពអប់រំស្ត្រីមាន NAPA និង CWPD-GFATM-R7 ។ ដៃគូសុខភាពសាធារណៈមាន មណ្ឌលសុខភាព វាំងព្រះស្រែ ស្ថិតក្នុងស្រុកប្រតិបត្តិឧដុង្គ។ មណ្ឌលសុខភាពរកាទេព ស្ថិតក្នុងស្រុកប្រតិបត្តិកំពង់ស្ពឺ។ ចំពោះអង្គការវិញមានអង្គការ វ៉ាក់ ដែលផ្តល់សេវាព្យាបាលមេរោគអេដស៍នៅគ្លីនិក World Vision។

**ខេត្តកំពង់ឆ្នាំង:** អ្នកផ្តល់សេសុខភាពសាធារណ គឺមន្ទីរពេទ្យបង្អែកខេត្តកំពង់ឆ្នាំង។

**ខេត្តបាត់ដំបង:** អង្គការដៃគូដែលផ្តល់ ការអប់រំ ដល់ស្ត្រីគឺ អង្គការ MHSS. អង្គការដៃគូដែលផ្តល់សេវាសុខភាព ដល់ស្ត្រីគឺ អង្គការ RHAC, Marie Stopes International Cambodia. អ្នកផ្តល់សេវារដ្ឋមាន គ្លីនិកគ្រួសារ មន្ទីរពេទ្យខេត្ត មណ្ឌលសុខភាពទួលតាឯក មណ្ឌលសុខភាពស្វាយប៉ោ មន្ទីរពេទ្យបង្អែកបាត់ដំបងក្នុងស្រុកប្រតិបត្តិបាត់ដំបង មណ្ឌលសុខភាពមោងឫស្សីក្នុងស្រុកប្រតិបត្តិមោងឫស្សី។

**ខេត្តសៀមរាប:** ដៃគូអនុវត្តន៍សកម្មភាពអប់រំមាន MHC, RHAC, និង APHESIP។ ចំពោះអង្គការអ្នកផ្តល់សេវាមាន RHAC និង Marie Stopes International រីឯស្ថាប័នរដ្ឋដែលផ្តល់សេវាមាន គ្លីនិកគ្រួសារមណ្ឌលមួយ មន្ទីរពេទ្យបង្អែកសៀមរាបក្នុងស្រុកប្រតិបត្តិសៀមរាប។

**ខេត្តប៉ៃលិន** ដៃគូរដ្ឋដែលផ្តល់សេវាសុខភាពមាន គ្លីនិកគ្រួសារ មន្ទីរពេទ្យប៉ៃលិន មណ្ឌលសុខភាពផ្សារព្រំ មណ្ឌលសុខភាពអូចារ និងស្រុកប្រតិបត្តិ ប៉ៃលិន។

**ខេត្តកណ្តាល** មន្ទីរពេទ្យបង្អែកជ័យជំនះ មន្ទីរពេទ្យបង្អែកកៀនស្វាយ ក្នុងស្រុកប្រតិបត្តិកៀនស្វាយ។ អង្គការមាន ម៉ារីស្តុប និង អាតិច ភីអេសហ្វេស (ATECT-PSF) ។

## B. វត្ថុបំណងនៃកម្មវិធី

ធ្វើអោយប្រសើរឡើង សុខភាពផ្លូវភេទ និងសុខមាលភាពទូទៅរបស់ស្ត្រីធ្វើការក្នុងសេវាកំសាន្ត និងបុរសជាសង្សារ បុគ្គលិកកាស៊ីណូ តាមរយៈ គំនិតច្នៃប្រឌិត និងគោរពយ៉ាងពិសិទ្ធដល់សិទ្ធិមនុស្សជាមូលដ្ឋាននិងកម្មវិធី សុខភាពផ្លូវភេទដែលបានទទួលស្គាល់ហើយនោះ។

### យុទ្ធសាស្ត្ររបស់គំរោង

1. អនុវត្តន៍សំដៅ ទៅលើវិធីសាស្ត្រកត់សំគាល់ការផ្លាស់ប្តូរការប្រព្រឹត្តសំរាប់អនុក្រុមនៃស្ត្រីធ្វើការ ក្នុងសេវាកំសាន្ត ដែលសង្កធ្ងន់លើការកាត់បន្ថយការប្រឈមមុខខ្ពស់ និង លើកកំពស់ការអនុវត្តន៍សុវត្ថិភាពផ្លូវភេទ។
2. លើកកំពស់និងបញ្ជ្រើនការទទួលសេវាសុខភាព សេវាព័តមាន និងផលិតផល ក្នុងចំណោមស្ត្រី ធ្វើការសេវាកំសាន្ត និងដៃគូ។
3. កសាងបរិយាកាសគាំទ្រសំរាប់សុខភាពផ្លូវភេទរបស់ ស្ត្រីធ្វើការក្នុងសេវាកំសាន្ត តាមរយៈ អ្នកពាក់ព័ន្ធដូចជា ម្ចាស់គ្រឹះស្ថាន ប៉ូលីស អ្នកផ្តល់សេវា និង អ្នកដទៃ។
4. កសាងសមត្ថភាពដល់បុគ្គលិកភ្នាក់ងារអនុវត្តន៍គំរោង ដៃគូ និងអ្នកពាក់ព័ន្ធក្នុងការធ្វើផែនទី អនុវត្តការងារ ការគ្រប់គ្រង និងតាមដានពិនិត្យកម្មវិធី។

# III. ការអនុវត្តគំរោង

## A. លទ្ធផលនាឆ្នាំ២០១១

*យុទ្ធសាស្ត្រទី១៖ លើកកំពស់និងបង្កើនការទទួលសេវាសុខភាព សេវាព័តមាន និងផលិតផល ក្នុងចំណោមស្ត្រីធ្វើការសេវាកំសាន្ត និងដៃគូ។*

### a. វិធីសាស្ត្រធ្វើផែនទី

CWPD ធ្វើផែនទីដើម្បី តាមដានទីតាំងរបស់ក្រុមគោលដៅដែលធ្វើអោយខាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំង និងជំងឺអេដស៍សើស្បែកនិងកាមរោគ ការិយាល័យអេដស៍ខេត្ត និងផ្ទៀងផ្ទាត់ថា មិនមានគ្រឹះស្ថានណាមួយដែលគ្របដណ្តប់ដោយអង្គការលើសពីមួយទេ។ លើសពីនេះទៀតបុគ្គលិករបស់ CWPD បានធ្វើរបាយការណ៍ស្តីពីការបច្ចុប្បន្នភាពផែនទី ប្រចាំត្រីមាស ជូនដល់ផ្នែកដែលពាក់ព័ន្ធដូចខាងលើផងដែរ។

*តារាង១ ការធ្វើផែនទី ស្ត្រីបំរើសេវាកំសាន្ត និងគ្រឹះស្ថានគ្របដណ្តប់ដោយ CWPD ក្នុងឆ្នាំ២០១១*

| ខេត្ត | សរុបគ្រឹះស្ថានក្នុងតំបន់ | គ្របដណ្តប់ដោយCWPD | % គ្របដណ្តប់ដោយCWPD | ចំនួនEWs សរុប | គ្របដណ្តប់ដោយCWPD | % គ្របដណ្តប់ដោយCWPD |
|---|---|---|---|---|---|---|
| ភ្នំពេញ | 1,035 | 73 | 07 | 13,300 | 1,800 | 13.53 |
| សៀមរាប | 130 | 55 | 42 | 3,400 | 1,600 | 47.05 |
| បាត់ដំបង | 150 | 63 | 42 | 1,600 | 1,300 | 81.25 |
| កណ្តាល | 92 | 55 | 60 | 1,400 | 700 | 50 |
| កំពង់ស្ពឺ | 67 | 42 | 62 | 700 | 450 | 64.28 |
| កំពង់ឆ្នាំង | 43 | 43 | 100 | 470 | 450 | 95.74 |
| ប៉ៃលិន | 30 | 30 | 100 | 400 | 400 | 100 |
| សរុប: | 1,547 | 361 | 23 | 21,270 | 6,700 | 31.49 |

### b. ស្ត្រីធ្វើការក្នុងសេវាកំសាន្ត

ក្នុងឆ្នាំ២០១១ ស្ត្រីដែលទទួលបានការអប់រំតាមរយៈក្រុមការងារមានចំនួន ៧៥៣៧នាក់ (ក្នុងផែនការ៦៧០០នាក់) ដែលមានការកើនឡើង ៥ .៥៦%ធៀបនិងលទ្ធផលក្នុងឆ្នាំ២០១០។ លទ្ធផលកើនឡើងពីត្រីមាសមួយទៅត្រីមាសមួយ បញ្ជាក់ពីភាពប្តេជ្ញាចិត្តរបស់បុគ្គលិក និងប្រធានក្រុមស្មាតហ្វេីល។ CWPD បានធ្វើផែនទីគ្រឹះស្ថានចំនួន ៣៦១ (ឆ្នាំ២០១០) ទៅ ៣៩៤ (២០១១) រីឯកម្មវិធីអ្នកជាបុរសពិតចំនួនគ្រឹះស្ថានបានកើនឡើងពី ១០៩ទៅ១៨២។

ផែនការCWPD ក្នុងឆ្នាំ២០១១គឺអប់រំស្ត្រីអោយបាន៦៧០០។ ក្នុងត្រីមាសទី១ ឆ្នាំ២០១១ CWPD សំរេចបាន៦,៣៥០នាក់ (៩៤.៧៧%) និងចំនួនដង ១៧,១៧៩ដង(៨៥,៤៦%) បើប្រៀបធៀបទៅនឹងត្រីមាសទី៤គឺ ចំនួនស្ត្រីទទួលបានការអប់រំ ៧,៣៨៣នាក់(១១០.១៩%) និងចំនួនដងនៃការអប់រំ២០,១៩៤ដង(១០០.៤៦%) មានការកើនឡើងចំនួន ១៥.៤២%។




ប្រព័ន្ធនៃការតាមដាននិងវាយតំលៃបានជួយដល់សកម្មភាពអប់រំដល់ក្រុមគោលដៅ។ប្រធានសំរបសំរួលខេត្តបានធ្វើការតាមដានជារៀងរាល់សប្តាហ៍ និងវិភាគទៅលើទិន្នន័យ រកដំណោះស្រាយ និងកែតំរូវផែនការ។

***ការដកស្រង់សំដីរបស់ប្រធានក្រុមស្មាតហ្វើល(ប្រធានក្រុមស្មាតហ្វើលកំពុងធ្វើការនៅភោជនីយដ្ឋានក្រុងអង្គរ)***



*រូបទី១ កញ្ញាជួន ស្រីឡា ប្រធានក្រុមស្មាតហ្វើល ខេត្តសៀមរាប*

ខ្ញុំជាប្រធានក្រុមស្មាតហ្វើលក្នុងខេត្ត សៀមរាប។ខ្ញុំ បានបណ្តុះបណ្តាលដោយ អង្គការ FHI 360 និង CWPD បន្ទាប់មក ធ្វើការជាមួយគ្រឹះស្ថានចំនួន៩ និងអប់រំដែលក្នុងមួយវគ្គៗមានស្ត្រីធ្វើការសេវាកំសាន្តចំនួន១២ទៅ១៨។ ខ្ញុំប្រើប័ណ្ណពណ៌និងលេខទូរស័ព្ទសំរាប់សំគាល់អ្នកចូលរួមថ្មី។ នៅបញ្ចប់វគ្គនីមួយៗខ្ញុំចែកប័ណ្ណបញ្ជូនជាមួយការណាត់ថ្ងៃទៅទទួលសេវា។ខ្ញុំត្រូវផ្សព្វផ្សាយផងដែរអំពីស្រោមអនាម័យ ព្រោះវាការពារពីការ ឆ្លងមេរោគអេដស៍ និងជម្ងឺកាមរោគ។ខ្ញុំរីករាយណាស់ ខ្ញុំជាស្មាតហ្វើល មានការងារមួយសមរម្យ និងមានមោទនភាពដោយបានបង្កើនចំនេះដឹងទាក់ទងនឹងសុខភាពបន្តពូជ ការកំណត់គោលដៅផ្ទាល់ខ្លួន និងការប្រើប្រាស់សំភារៈអប់រំ ប្រចាំត្រីមាស។ចំពោះស្ត្រីមួយចំនួនពិបាកក្នុងការបញ្ជូនទៅកាន់សេវាសុខភាពព្រោះពួកគាត់ធ្វើការនាពេលយប់ ងងុយគេងពេលថ្ងៃ។

### c. បុគ្គលិកកាស៊ីណូ

បុគ្គលិកកម្មវិធី CWPD និងអ្នកសំរបសំរួល ផ្តល់វគ្គអប់រំស្តីពីសុខភាពបន្តពូជដល់បុគ្គលិកកាស៊ីណូចំនួន ១៩០០នាក់ ក្នុងកាស៊ីណូចំនួន ៨ក្នុងខេត្តប៉ៃលិន និង១កាស៊ីណូក្នុងរាជធានីភ្នំពេញ។

**Figure 2: numbers of CWs reached/contacts by quarters, 2011**



វគ្គអប់រំជាផ្លូវការត្រូវបានធ្វើចំនួនពី២ទៅ៤ដងក្នុង១ខែនៅកាស៊ីណូនីមួយៗក្នុងរយៈពេលជាមធ្យមពី២០ទៅ៣០នាទី។ ចំនួនបុគ្គលិកកាស៊ីណូដែលទទួលការអប់រំប្រចាំត្រីមាសក្នុងផែនការសំរាប់ ឆ្នាំ២០១១ មានចំនួន ១៩០០នាក់។ ជាលទ្ធផលក្នុងត្រីមាសទី១ឆ្នាំ២០១១សំរេចបានចំនួន ១៣០០នាក់(៧០.៧៣%) ចំនួន ដងនៃការអប់រំមានចំនួន៣,៤០១ដង (៨៩.៥០%)បើប្រៀបធៀបនិងត្រីមាសទី៤ក្នុងឆ្នាំ ២០១១ ដែលមានចំនួនការអប់រំ និងចំនួនដងកើនឡើង៤៣.៦៣% ។



*រូបភាពទី២: វគ្គអប់រំជាក្រុមបុគ្គលិកកាស៊ីណូខេត្តប៉ៃលិន*

អ្នកសំរបសំរួលកាស៊ីណូ ជនបង្គោលកាស៊ីណូ និង បុគ្គលិកគំពោង ផ្តល់ការអប់រំជាបុគ្គល និងជា ក្រុមទាក់ទងនិងប្រធានបទសុខភាពផ្លូវភេទ និងការកាត់បន្ថយការប្រឈម។ ជនបង្គោលកាស៊ីណូដើរតួនាទីជាអ្នកគាំទ្រកម្មវិធីក្នុងការផ្តល់ការសំរបសំរួលដល់វគ្គអប់រំ ។ប្រធានសំរបសំរួលខេត្តបាន ធ្វើការតាមដានជារៀងរាល់សប្តាហ៍និងវិភាគទៅលើទិន្នន័យរកដំណោះស្រាយ និងកែតំរូវផែនការ។

### d. អតិថិជនបុរស និងកម្មវិធីអ្នកជាបុរសពិត

បុគ្គលិកអ្នកស្ម័គ្រចិត្ត បានចុះធ្វើការអប់រំជាមួយបុរសជាអតិថិជនក្នុងគ្រឹះស្ថានសេវាកំសាន្ត វគ្គអប់រំត្រូវសង្ខេប និងមានលក្ខណៈកំសាន្តធ្វើឡើងបន្ទាប់ពីម៉ោង៥ល្ងាច និងក្នុងកំលុងពេលថ្ងៃត្រង់ ។ CWPD បានប្រើប្រាស់សំភារៈដែលបង្កើតដោយFHI360 ។

*តារាង២ ចំនួនបុរសទទួលការអប់រំជាបុគ្គល និងក្រុមតូចតាមរយៈកម្មវិធីអ្នកជាបុរសពិត*

| ខេត្ត | FY2011 ផែនការ | Q1-FY2011 | Q2-FY2011 | Q3-FY2011 | Q3-FY2011 | Total FY2011 | % |
|---|---|---|---|---|---|---|---|
| ភ្នំពេញ | 10,000 | 4,478 | 4,848 | 4,234 | 3,637 | 17,197 | 171.97% |
| សៀមរាប | 15,000 | 4,546 | 4,978 | 4,596 | 4,932 | 19,052 | 127.01% |
| បាត់ដំបង | 15,000 | 4,925 | 5,768 | 5,573 | 5,026 | 21,292 | 141.94% |
| សរុប: | 40,000 | 13,949 | 15,594 | 14,403 | 13,595 | 57,541 | 143.85% |

ក្នុងឆ្នាំ២០១១ កម្មវិធីអ្នកជាបុរសពិតរបស់CWPD មាននៅក្នុងខេត្តបាត់ដំបង សៀមរាប និងក្រុងភ្នំពេញ។ ចំពោះកម្មវិធីទូរទស្សន៍អ្នកជាបុរសពិត CWPD បានចែកពាក្យចំនួណ៥,០០០ពាក្យ និងមានបេក្ខជនមកដាក់ពាក្យចំនួន ១,៧៦៩។

### e. អ្នកប្រើប្រាស់គ្រឿងញៀន

អ្នកអប់រំគ្រឿងញៀនចុះទៅអប់រំ (ជាមួយរឺផ្សេងពីក្រុមផ្សេងពីស្មាតហ្គើលតាមតំរូវការក្រុម) ផ្តល់កញ្ចប់សេវាទៅកាន់អ្នកប្រើប្រាស់គ្រឿងញៀនចំនួន៥០០នាក់ ក្នុងខេត្តចំនួន៣ ដែលត្រូវបានកំណត់ថាជាតំបន់ងាយរងគ្រោះ រាប់បញ្ចូលទាំងការប៉ាន់ប្រមាណការប្រឈមមុខ ធ្វើការផ្តល់សារកាត់បន្ថយគ្រោះថ្នាក់ និងផ្តល់ប័ណ្ណបញ្ជូន។ ខណៈពេលCWPDមានក្រុមគោលដៅជាអ្នកប្រើប្រាស់គ្រឿងញៀនចំនួន៥០០នាក់ អង្គការ FHI 360បានជ្រើសរើសទីតាំងភ្នំពេញក្នុងការអនុវត្តគំរោង HR និង NSP ដូចនេះចំនួនក្រុមគោលដៅនៅត្រឹមតែ២៥០នាក់។ CWPD សំរេចបានការអប់រំក្រុមគោលដៅDU/IDUចំនួន១០៨នាក់ និងចំនួនដងនៃការអប់រំ២៣៨។




CWPDខេត្តសៀមរាបៈ បានរាយការណ៍ថាក្រុមជួយខ្លួនឯង ដែលមានសមាជិកចំនួន២៤នាក់បានប្រជុំជាទៀងទាត់កំពុងបារម្ភអំពីអន្តរាគមន៍ពីសំណាក់គោលនយោបាយភូមិឃុំមានសុវត្ថិភាព ឧទាហរណ៍ដូចជារបាយការណ៍មួយដែលបានផ្ញើទៅកាន់អង្គការFHI360 នាថ្ងៃ ១១ ឧសភា ២០១១ ស្តីពីការចាប់ខ្លួនស្ត្រីជាអ្នកប្រើប្រាស់គ្រឿងញៀន ។ ចំនួនអប់រំមិនគ្រប់គោលដៅក៏អាស្រ័យដោយមូលហេតុមួយផ្សេងទៀតគឺ ស្ត្រីមិនហ៊ានចេញមុខដោយខ្លាចថៅកែហាងដឹងរួចបញ្ឈប់ខ្លួនពីការងារ ។ ចំពោះខេត្តបាត់ដំបងសំនូមពរអោយធ្វើការយ៉ាងជិតស្និតជាមួយសង្កាត់ស្វាយប៉ោ និង ក្រុងបាត់ដំបង ដើម្បីអនុគ្គន៏ការអប់រំទៅកាន់អ្នកប្រើប្រាស់គ្រឿងញៀនស្របតាមគោលការណ៍ NCD និងសំរេចបានការអប់រំស្ត្រីប្រើប្រាស់គ្រឿងញៀន។

### f. ក្លឹបស្មាតហ្គើល

ក្លឹបស្មាតហ្គើលជាមណ្ឌលសំចតសំរាប់ស្ត្រីធ្វើការក្នុងសេវាកំសាន្តអាចទទួលការផ្តល់ប្រឹក្សាអំពីមេរោគអេដស៍ ជំងឺកាមរោគ និងសេវាតេស្តឈាមរកមេរោគអេដស៍។ គ្រប់សមាជិកស្មាតហ្គើលទាំងអស់អាចមកលេងក្លឹបប្រើប្រាស់គ្រឿងសំអាង។CWPDបានកំនត់ផែនការថាស្ត្រីចំនួន ៦២.៦៨% នឹងក្លាយជាសមាជិកស្មាតហ្គើលក្លឹបក្នុងឆ្នាំ២០១១និងចំនួនសមាជិកសរុបគិតត្រឹមឆ្នាំ ២០១១ គឺ ៨៣.៩៨%។ ស្មាតហ្គើលក្លឹបរបស់ CWPDមាននៅទីក្រុងភ្នំពេញ ក្រុងបាត់ដំបង និងក្រុងសៀមរាបបានដើរតួនាទីក្នុងការជំរុញការទៅទទួលសេវាសុខភាពរបស់ស្ត្រី។ ក្នុងមួយសប្តាហ៍ម្តងវគ្គអប់រំមួយក្រុមត្រូវបានធ្វើនៅក្នុងក្លឹប និងព្រឹត្តិការណ៍ពិសេសក្នុងរយៈ៣ខែម្តង។ ការក្លាយជាសមាជិកស្មាតហ្គើលក្លឹបអាចអោយស្ត្រីស្គាល់មិត្តថ្មី និងអាចជួយអោយពួកគេពិភាក្សាគ្នាដោយការបើកបេះដូង

ចំពោះបញ្ហា សុខភាព ការទៅទទួលសេវានៅគ្លីនិក ក៏ដូចជាការ ផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមក។

នៅក្នុងឆ្នាំ២០១១ CWPD គ្រោងបង្កើនចំនួនសមាជិក ដល់៥០%នៃស្ត្រីដែលទទួលបានការអប់រំ និងសមាជិកក្លឹបដល់ ៥០% ដែលមកលេងក្លឹប ក្នុងមួយត្រីមាស។



*រូបភាពទី៣: សកម្មភាពក្លឹបនាខេត្តបាត់ដំបង*

*តារាងទី៣ ចំនួនសមាជិកក្លឹប (បូកបន្ត) និង សរុបចំនួនស្ត្រីមកលេង ក្លឹប*

| ទីតាំងក្លឹប | ផែនការ FY2011 | សមាជិកក្លឹប | | | សកម្មភាពក្នុងក្លឹប អ្នកមកក្លឹប ក្នុងត្រីមាសមុន | | |
|---|---|---|---|---|---|---|---|
| | | ចំនួន EWs | # of EWs កើនឡើង | % of EWs កើនឡើង | ក្រុមគោលដៅ | # សមាជិកមកលង | % សមាជិកមកលង |
| ភ្នំពេញ | 900 | 1,100 | 200 | 22.22% | 450 | 460 | 102.22% |
| សៀមរាប | 800 | 1,586 | 786 | 98.25% | 400 | 249 | 62.25% |
| បាត់ដំបង | 650 | 1,514 | 864 | 132.92% | 325 | 277 | 85.23% |

**CWPD** ខេត្តសៀមរាប:

ក្លឹបគួរនៅជិតកន្លែងធ្វើការរបស់ស្ត្រីបំរើសេវាកំសាន្ត ក៏ប៉ុន្តែតំលៃនៃការជួលកន្លែងនៅក្នុងតំបន់សេដ្ឋកិច្ចបែបនេះវាមានតំលៃខ្ពស់លើសពីថវិកាគំរោង ។ ចំពោះបញ្ហាការរក្សាទុកដាក់ កាតសមាជិកស្មាតហ្គើលបុគ្គលិកខេត្តសៀមរាបបានចោះប្រហោងសំរាប់យកទៅធ្វើបន្ទោងកូនសោរ។

**CWPD** បាត់ដំបង:

ស្មាតហ្គើលធ្វើការនាពេលថ្ងៃមួយចំនួនមិនអាចមកលេងក្លឹបព្រោះម្ចាស់គ្រឹះស្ថានមិនអនុញ្ញាត រីឯស្ត្រីដែលធ្វើការនាពេលរាត្រីមួយចំនួនក៏មិនអាចមកលេងក្លឹបបានដែរព្រោះងងុយគេង។

### g. កាតសមាជិកស្មាតហ្គើល

CWPD ខេត្តកណ្តាលៈ កាតសមាជិកស្មាតហ្គើល បានចែកចំនួន១០៥៤ ដល់ស្ត្រីចំនួន៩៦៣ នាក់ក្នុងផែនទីនៃត្រីមាសទីក្នុងឆ្នាំ២០១១។ ២០%នៃស្ត្រីចំនួន១០០នាក់ក្នុងខារ៉ាអូខេតារាត្រជាក់ចិត្ត បានស្គាល់កូដរបស់ខ្លួនប៉ុន្តែចំពោះហាងម៉ាស្សាដែលមានស្ត្រីចំនួនតិចជាង១០នាក់បានស្គាល់លេខកូដទាំង១០០%។ ប្រធានក្រុមស្មាតហ្គើលបានប្រើប្រាស់ម៉ាស៊្វរលើស សំរាប់គ្រប់គ្រងលេខកូដរបស់ស្ត្រី។ ស្ត្រីបាននិយាយថាអ្នកដែលមានលេខកូដនៅគ្រឹះស្ថានខ្លួនធ្វើការរួចនៅពេលវគ្គអប់រំពួកគេត្រូវ ប្រើលេខកូដស្មាតហ្គើល មានផលលំបាកសំរាប់ពួកគេ និងមានការភាន់ច្រលំ។ជាមួយនិងការកើនឡើងចំនួនស្ត្រីយល់ដឹងពីសារៈប្រយោជន៍នៃការទៅពិនិត្យសុខភាព ប្រធានក្រុមស្មាតហ្គើលត្រូវរំលឹកស្ត្រីដែលទៅទទួលសេវាកាលពីខែមុន អំពីកម្មវិធីកាតសំណាងល្អសុខភាពល្អ។

### h. សារទូរស័ព្ទ

សមាជិកក្លឹបស្មាតហ្គើលទាំងអស់ទទួលបានសារតាមរយៈទូរស័ព្ទក្នុង២សប្តាហ៍ម្តង។ សារទាំងនោះនិងធ្វើជាមួយដៃគូស្ត្រីនិងផ្ញើរទៅកាន់សមាជិកក្លឹបតាមរយៈអ្នកគ្រប់គ្រងក្លឹប

*តារាង៤ ការផ្ញើសារតាមរយៈទូរស័ព្ទ*

| ខេត្ត | ផែនការ | សារបានផ្ញើ | % |
|---|---|---|---|
| ភ្នំពេញ | 900 | 494 | 54.88 |
| សៀមរាប | 800 | 669 | 83.62 |
| បាត់ដំបង | 650 | 831 | 127.84 |
| សរុបៈ | 2,350 | 1,994 | 84.85 |

## *យុទ្ធសាស្ត្រទី២៖ លើកកំពស់និងបង្កើនការទទួលសេវាសុខភាព សេវាព័តមាន និងផលិតផល ក្នុងចំណោមស្ត្រីធ្វើការសេវាកំសាន្ត និងដៃគូ។*

### a. ស្រោមអនាម័យៈ ការធ្វើទីផ្សារស្រោមអនាម័យនិងការចែកដោយឥតគិតថ្លៃ

CWPD បានលក់ស្រោម អនាម័យចំនួន ៣៥៦,៨៥៨ ស្រោមទៅកាន់ស្ត្រីធ្វើការសេវាកំសាន្តដែលស្មើនឹង ៣៤៩.៨៦% នៃផែនការ ចំនួន១០២,០០០ ស្រោម។ CWPDក៏បានធ្វើទីផ្សារស្រោមអនាម័យក្នុងវិស័យឯកជនផងដែរ (កាស៊ីណូ) ដែលមានចំនួនសរុប១៦៣២៤ស្រោម (ក្នុងផែនការ ៨,០០០ស្រោម)ស្មើនឹង២០៤.៥%។ចំពោះការលក់ស្រោមអនាម័យនៅកាស៊ីណូចាប់ផ្តើមធ្វើក្រោយគំរោងទាំងមូលចាប់បផ្តើមនៅភ្នំពេញ២ខែ។

CWPDបានចែកស្រោមអនាម័យចំនួន ១៦៣,១៤ស្រោម ទៅកាន់ស្ត្រីធ្វើការក្នុងសេវាកំសាន្តស្មើនិង៧៩.៩៧% នៃផែនការសរុប ២០៤ ,០០០ ។ ចំពោះកាស៊ីណូវិញចែកបាន ១៤ ,៩៧១% ស្មើនឹង៩៣.៥៦%នៃផែនការសរុប ១៦,០០០ស្រោម។ ចំពោះការដែលសំរេចផែនការនេះព្រោះ CWPD មិនបានទទួលនូវការផ្គត់ផ្គង់ស្រោមគ្រប់ចំនួនពីអង្គការFHI 360។ ខណៈពេលដែលដាច់ស្តុកស្រោមអនាម័យ យើងបានអោយស្ត្រីទិញ ស្រោមអនាម័យ ចៀសជាងរង់ចាំការចែក។

### b. កញ្ចប់អប់រំ

កម្មវិធីអប់រំគឺជាយុទ្ធសាស្ត្រផ្តួចផ្តើមថ្មីមួយដែលត្រូវបានអនុវត្តក្នុងការធ្វើអោយរាល់សកម្មភាពសំរេចបានគោលដៅក្នុងឆ្នាំ២០១១និងធ្វើអោយប្រធានក្រុមស្មាតហ្គើលសំរេចបានការងាររបស់គេ។ ធាតុក្នុងកញ្ចប់អប់រំមានផ្តល់ការអប់រំ ការបញ្ជូនទៅទទួលសេវាសុខភាព ការចែកនិង រឺលក់ស្រោមអនាម័យ។ នៅពេលយើងអនុវត្តយុទ្ធសាស្ត្រកញ្ចប់នៃការអប់រំចាប់តាំងពីត្រីមាសទីពីរនៃឆ្នាំ២០១១មក មានការកើនឡើងនូវលទ្ធផលដូចមានបង្ហាញក្នុងតារាងខាងក្រោម




**Figure 4:*Components of the Core Packages***

### c. លទ្ធផលនៃការបញ្ជូនទៅសេវាសុខភាព

នៅពេលក្រុមអប់រំប្រធានក្រុមស្មាតហ្គើលនិងអ្នកសំរបសំរួលគំរោងជួបជាមួយស្ត្រី តាមរយ សកម្មភាពអប់រំ ពួកគេប្រាកដថាបានលើកទឹកចិត្តស្ត្រីក្នុងការទៅពិនិត្យសុខភាព ផ្តល់ប័ណ្ណបញ្ជូននិងផ្តល់ព័តមានដល់ពួកគេអំពីផលប្រយោជន៍ទៅទទួលសេវាសុខភាព។ តាមរយៈប្រព័ន្ធនៃការបញ្ជូននេះ CWPD បានបញ្ជូនទៅគ្លីនិកគ្រួសារ ម៉ាក់ម៉ារីស្តុប ឈូកស មិច និង អ្នកផ្តល់សេវាផ្សេងៗទៀត។ បុគ្គលិក CWPD បានប្រមូលប័ណ្ណបញ្ជូនទាំងនោះរៀងរាល់ខែ ដោយធ្វើចំណាត់ថ្នាក់តាមប្រភេទសេវា ។ ចំពោះស្ត្រីយកមកវិញនូវចុងសន្លឹកផ្នែកទី៣នៃប័ណ្ណបញ្ជូនរួចដាក់ក្នុងប្រអប់សំរាប់ចាប់ឆ្នោតប្រចាំត្រីមាស។

*ការទៅទទួលសេវាជាបុគ្គលក្នុងត្រីមាសទី២នាឆ្នាំ២០១១ដោយប្រើម៉ាស្វ័រលើស*







*សកម្មភាព* Fastest *បានជួយអោយជោគជ័យដល់ ផែនការ* VCCT *នាឆ្នាំ២០១១* ***ទិន្នន័យការទៅទទួលសេវា ពីបុគ្គលិកកាស៊ីណូតាំងពីត្រីមាសទី១ឆ្នាំ២០១១ប៉ុន្តែការអនុវត្តប្រើប្រាស់ម៉ាស្ទ័រលើស ទើបតែចាប់ផ្តើមនាត្រីមាសទី២។***

### d. *ការទៅទទួលសេវាសុខភាពពី ស្ត្រីធ្វើការសេវាកំសាន្ត និង បុគ្គលិកកាស៊ីណូ*

តាមរយៈប្រព័ន្ធនៃការបញ្ជូន CWPD បានបញ្ជូនទៅគ្លីនិករដ្ឋ រ៉ាក់ ម៉ារីស្តុប ឈូកស មិច និង អ្នកផ្តល់សេវាដទៃទៀត។ ចំនួននៃការទៅទទួលសេវា អាស្រ័យទៅលើៈ*១ **សិទ្ធិរបស់បុគ្គលក្នុងការជ្រើសរើសសេវាសុខភាព, ២ ទីតាំងនៃកន្លែងផ្តល់សេវា(ជិតឆ្ងាយ), ៣ គុណភាពនៃសេវា(សំភារៈ និងការរង់ចាំ)** ។*

Figure 7: % health services uptakes of EWs and CWs:

EWs CWs







តារាងទី៥: ការទៅទទួលសេវាកាមរោគ នាឆ្នាំ២០១១

| តំបន់គោលដៅ | ក្រុមគោលដៅ 2011 | ជាជាបុគ្គល 2011 | ចំនួនដង 2011 | ចំនួន% | ចំនួនដងជាមធ្យម |
|---|---|---|---|---|---|
| ភ្នំពេញ | 1,350 | 810 | 1,810 | 60 | 2.23 |
| សៀមរាប | 1,200 | 895 | 1,586 | 74.58 | 1.77 |
| បាត់ដំបង | 975 | 736 | 1,879 | 75.48 | 2.55 |
| កណ្តាល | 525 | 559 | 1,943 | 106.47 | 3.47 |
| កំពង់ស្ពឺ | 338 | 352 | 948 | 104.14 | 2.69 |
| កំពង់ឆ្នាំង | 338 | 400 | 1,138 | 118.34 | 2.84 |
| ប៉ៃលិន | 300 | 412 | 981 | 137.33 | 2.38 |
| កាស៊ីណូភ្នំពេញ | 350 | 631 | 792 | 180.28 | 1.25 |
| កាស៊ីណូប៉ៃលិន | 315 | 678 | 848 | 215.23 | 1.25 |
| សរុប: | 5,691 | 5,473 | 11,925 | 96.16 | 2.17 |

តារាងទី 6: ការទៅទទួលសេវាតេស្តឈាមរកមេរោគអេដស៍ឆ្នាំ២០១១

| តំបន់គោលដៅ | ក្រុមគោលដៅ 2011 | ជាជាបុគ្គល 2011 | ចំនួនដង 2011 | ចំនួន% | ចំនួនដងជាមធ្យម |
|---|---|---|---|---|---|
| ភ្នំពេញ | 900 | 793 | 1,583 | 88.11 | 1.99 |
| សៀមរាប | 800 | 1,164 | 1,512 | 145.50 | 1.29 |
| បាត់ដំបង | 650 | 426 | 812 | 65.53 | 1.90 |
| កណ្តាល | 350 | 302 | 663 | 86.28 | 2.19 |
| កំពង់ស្ពឺ | 225 | 209 | 356 | 92.88 | 1.70 |
| កំពង់ឆ្នាំង | 225 | 208 | 416 | 92.44 | 2.00 |
| ប៉ៃលិន | 200 | 234 | 395 | 117.00 | 1.68 |
| កាស៊ីណូភ្នំពេញ | 200 | 164 | 189 | 82.00 | 1.15 |
| កាស៊ីណូប៉ៃលិន | 180 | 191 | 198 | 106.00 | 1.03 |
| សរុប: | 3,730 | 3,691 | 6,124 | 98,95 | 1.65 |

*កិច្ចសហការគ្នាល្អរវាង CWPD និង អ្នកផ្តល់សេវា VCCT រដ្ឋ បានជួយដល់សុចនករប្រចាំឆ្នាំ ក៏ប៉ុន្តែការប្រើប្រាស់ម្ជុលធំ បានធ្វើអោយស្ត្រីមួយចំនួនមិនសប្បាយចិត្ត*

តារាងទី**៧**: ការទៅទទួលសេវាតេស្តឈាមរកមេរោគអេដស៍ឆ្នាំ២០១១

| តំបន់គោលដៅ | ក្រុមគោលដៅ 2011 | ជាជាបុគ្គល 2011 | ចំនួនដង 2011 | ចំនួន% | ចំនួនដងជាមធ្យម |
|---|---|---|---|---|---|
| ភ្នំពេញ | 540 | 620 | 985 | 114.81 | 1.59 |
| សៀមរាប | 480 | 69 | 108 | 14.37 | 1.57 |
| បាត់ដំបង | 390 | 182 | 269 | 46.66 | 1.48 |
| កណ្ដាល | 210 | 60 | 122 | 28.57 | 2.03 |
| កំពង់ស្ពឺ | 135 | 76 | 124 | 56.29 | 1.63 |
| កំពង់ឆ្នាំង | 135 | 70 | 140 | 51.85 | 2.00 |
| ប៉ៃលិន | 120 | 72 | 87 | 60.00 | 1.21 |
| កាស៊ីណូភ្នំពេញ | 200 | 209 | 240 | 104.59 | 1.51 |
| កាស៊ីណូប៉ៃលិន | 180 | 215 | 282 | 119.44 | 1.31 |
| សរុប: | 2,390 | 1,573 | 2,357 | 65.81 | 1.49 |

*ចំពោះស្ត្រីក្មេងៗមួយចំនួននៅពេលចង់ប្រើប្រាស់មធ្យោបាយពន្យារកំណើតដូចជាថ្នាំគ្រាប់ពួកគាត់បានទៅទិញនៅឱសថស្ថាន ជាហេតុធ្វើអោយតួលេខការបញ្ជូនស្ត្រីទៅទទួលសេវានេះធ្លាក់ចុះៗ* ស្ត្រីមានសិទ្ធិក្នុងការជ្រើសរើស ទាំងគ្លីនិករដ្ឋ និង គ្លីនិកជន






### e. *កាតសុខភាពល្អសំណាងល្អ*

កាតសុខភាពល្អសំណាងល្អជាប្រព័ន្ធនៃការផ្ដល់រង្វាន់ និង តាមដានចំពោះការអនុវត្តន៍ការទៅទទួលសេវាពីសំណាក់ស្ត្រីធ្វើការក្នុងសេវាកំសាន្ត និងការលើកទឹកចិត្ត អោយគាត់ទៅទទួលសេវាច្រើនក្នុងពេលតែមួយ។កាតសុខភាពល្អសំណាងល្អត្រូវបានប្រមូលជារៀងរាល់៦ខែម្ដងពីក្រុមគោលដៅនិង ការចាប់រង្វាន់ធ្វើឡើងក្នុងព្រឹត្តិការណ៍ពិសេសនៅត្រីមាសទី២ និងទី៤ក្នុងក្លឹបស្មាតហ្គើល។

តារាងទី៨: កាតសំណាងល្អសុខភាពល្អដែលបានចែកចាយ និងប្រមូល

| Project Sites | Loyalty Card Distributed | Loyalty Card Collected | # of Service Provided | | | Remark |
|---|---|---|---|---|---|---|
| | | | STI | VCCT | RH/FP | |
| CWPD-PHP | 1950 | 118 | 110 | 82 | 84 | Gold Points Earned: 18s, 18p<br>Silver Points Earned: 77s, 75p<br>Bronze Points Earned: 14s 14p |
| CWPD-SRP | 1000 | 246 | 349 | 308 | 47 | Gold Points Earned:38s, 38p<br>Silver Points Earned:218s, 218p<br>Bronze Points Earned:43s, 43p |
| CWPD-BTB | 609 | 499 | 441 | 270 | 115 | Gold Points Earned:70s, 70p<br>Silver Points Earned:162s, 167p<br>Bronze Points Earned:262s, 267p |
| CWPD-KDL | 950 | 39 | 38 | 24 | 17 | Gold Points Earned: 06s, 06p<br>Silver Points Earned:28s, 28p<br>Bronze Points Earned:06s, 06p |
| CWPD-KPS | 930 | 84 | 92 | 54 | 23 | Gold Points Earned: 14s, 14p<br>Silver Points Earned:45s, 45p<br>Bronze Points Earned:30s, 30p |
| CWPD-KPC | 816 | 172 | 229 | 160 | 15 | Gold Points Earned: 13s, 13p<br>Silver Points Earned:147s, 147p<br>Bronze Points Earned:15s, 15p |
| CWPD-PL | 1050 | 170 | 136 | 79 | 45 | Gold Points Earned: 15s, 15p<br>Silver Points Earned:60s, 60p<br>Bronze Points Earned:95s, 95p |
| Total | 7305 | 1328 | 1395 | 977 | 346 | |

ក្នុងឆ្នាំ២០១១ CWPD បានប្រារព្ធព្រឹត្តិការណ៍ពិសេសក្នុង៧កន្លែងលើកលែងតែកាស៊ីណូនារាជធានីភ្នំពេញ ព្រោះបុគ្គលិកកាស៊ីណូធ្វើការបន្ថែមម៉ោងនាថ្ងៃព្រឹត្តិការណ៍ពិសេសអង្គFHI360 បានធ្វើការសាកល្បង ជាមួយកាតសំណាងល្អសុខភាពល្អចាប់ពីត្រីមាសទីពីរនាឆ្នាំ២០១០ ដើម្បីជំរុញស្ត្រីអោយ ទៅទទួលសេវាសុខភាព។



***រូបថតទី ៦***

**សកម្មភាពព្រឹត្តិការណ៍ពិសេស កាតសំណាងល្អសុខភាពល្អ *CWPD* ខេត្ត បាត់ដំបង**

**f.**

## *កប្រើប្រាស់គ្រឿងញៀន*

កម្មវិធីកាត់បន្ថយ គ្រោះថ្នាក់លើអ្នកប្រើប្រាស់គ្រឿងញៀនជាមួយអ្នកអប់រំដែលក្នុងឆ្នាំ២០១១ នេះមានតែក្នុងខេត្តសៀមរាប និងបាត់ដំបង ដែលមានអ្នកអប់រំនិងអ្នកផ្តល់ប្រឹក្សាក្នុងខែវិច្ឆិកា ដល់ធ្នូ ឆ្នាំ២០១០។ក្លឹបស្អាតហ្វើលក្នុងខេត្តបាត់ដំបង និងសៀមរាប បានធ្វើការជួបប្រជុំអ្នកប្រើប្រាស់គ្រឿងញៀនពី១០ទៅ១២នាក់ ស្ត្រី ត្រូវបានលើកទឹកចិត្តអោយនាំដៃគូរបស់ខ្លួនផងដែរ។

កម្មវិធីគ្រឿងញៀននាក្រុងភ្នំពេញបានកាត់ទៅគំរោង GFATM-R7 ទាំងថវិកា និងទិន្នន័យ។

## *g. ក្រុមជួយខ្លួនឯង*








រូបថតទី ៧,៨ : សកម្មភាពប្រជុំក្រុមជួយខ្លួនឯង

*h. ប្រវត្តិរូប សារកាត់បន្ថយគ្រោះថ្នាក់ (BMI):*

អ្នកចូលរួមថ្មីក្នុងក្រុមជួយខ្លួនឯងម្នាក់ៗបានបំពេញនូវប្រវត្តិរូប(តាមការស្ម័គ្រចិត្ត) និងប៉ាន់ប្រមាណអំពីការប្រឈមមុខ និងការផ្ដល់ប្រឹក្សា។

តារាងទី៨: កាត ប្រវត្តិរូប សារកាត់បន្ថយគ្រោះថ្នាក់(BMI) ឆ្នាំ ២០១១

| Sites | #Personal Profile | # Risk Assessment | # BMI accumulative |
|---|---|---|---|
| CWPD-PHP | 94 | 79 | 923 |
| CWPD-SR | 58 | 160 | 58 |

| | | | |
|---|---|---|---|
| CWPD-BTB | 81 | 104 | 05 |
| CWPD | 233 | 343 | 986 |

**i.** ចំនួន DU/IDU បានទទួលសេវាសុខភាព (STI, VCCT) FY 2011




## *យុទ្ធសាស្ត្រទីពីរ៖ សាងបរិយាកាសគាំទ្រ ដល់សុខភាពផ្លូវភេទរបស់ក្រុមងាយរង គ្រោះ តាមរយៈចលនាអ្នកដែលពាក់ព័ន្ធដូចជាថ្នាក់ដឹកនាំការស៊ីណូ ម្ចាស់គ្រឹះស្ថាន ប៉ូលីស អ្នកផ្តល់សេវា*

ធ្វើឲ្យមានបរិយាកាសគាំទ្រចំពោះក្រុមងាយរងគ្រោះ តំណាងបណ្តាញស្មាតហ្គើលបានចូលរួមក្នុង ក្រុមការងារបង្ការ ថែទាំ និងព្យាបាលបន្ត(CoPCT) និងចូលរួមការប្រជុំថ្នាក់ ស្រុក/ខ័ណ្ឌ និង ថ្នាក់ជាតិរៀបចំដោយ អាជ្ញាធរជាតិប្រយុទ្ធជម្ងឺអេដស៍ NAA, NCHADS, UNAIDS, Medicam, RHAC ។

កម្មវិធីស្មាតហ្គើលបានភ្ជាប់ទំនាក់ទំនងជិតស្និទ្ធជាមួយក្រុមការងារថ្នាក់ជាតិក្រុមថែទាំបន្ត។ NAA បានទទួលស្គាល់ សមាគមនារីជាដៃគូធំជាងគេដែលធ្វើការងារផ្នែកការពារទប់ស្កាត់ជំងឺអេដស៍ និងកាត់បន្ថយការរើសអើងចំពោះស្ត្រីក្រុមគោលដៅ ។ មាគមនារីក៏បានចុះហត្ថលេខាអនុស្សរណៈលើការងារទប់ស្កាត់អេដសន៍ជាមួយ NAA និង ក្រសួងសុខាភិបាលផងដែរ ។

### a. បញ្ជីឈ្មោះគ្រឹះស្ថានផ្តល់ការគាំទ្រចំពោះគំរោង

**CWPD** បានកំនត់តួនាទីរបស់ម្ចាស់គ្រឹះស្ថានថាជាអ្នកគាំទ្រកម្មវិធី **SMARTgirl** របាយការណ៍ខាងក្រោមជាការធ្វើចំណាត់ថ្នាក់ម្ចាស់សេវា តាមខេត្ត:

**ខេត្តកំពង់ស្ពឺ:** ភោជនីយដ្ឋាន ម្លប់ដូង ម្លប់ទឹកដោះ ម្លប់ច័ន្ទ ម្លប់ក្រូច ពន្លកថ្មី អេង ណៃ ច័ន្ទគីរី ២ អូគីដេ ខារ៉ាអូខេ ភ្នំខៀវ ហូលីវូដ លីលី (សរុប១៣ក្នុងចំណោម ៤២គ្រឹះស្ថាន)

**ខេត្តបាត់ដំបង:** អង្គរបៀរប្រមូលសិន ខារ៉ាអូខេ ខេធីវីខេមរា ៥៥៥ កោះតៃវ៉ាន់ ហាងឡាយ កូប្រាហោភី មនោរម្យ ក្រូចសើច ប្រជាប្រិយ សុភមង្គល រស្មីគង្គា ត្រជាក់ចិត្តថ្មី (សរុប ១៣ក្នុងចំណោម ៦៣គ្រឹះស្ថាន)

**ខេត្តសៀមរាប:** ភោជនីយដ្ឋាន បាពូន មហានគរ មេបុណ្យ អេច ស្កាយ សែនសប្បាយ ១ ២ ៣ សេមប្រាឌ័រ ទីក្រុងអង្គរ មករា២ ម្លប់ស្បូវសៀមរាប សាច់អាំងវិមានទិព្វ ២ កន្លែង ម៉ាស្សា ខារ៉ាអូខេ ញូស្តា ពន្លឺព្រះច័ន្ទ ថប់ថោន បន្ទាយស្រី ក្លឹបហ្វូនវ៉ែន ប៉ាក់ខែង (សរុប ២១ ក្នុងចំណោម៥៦គ្រឹះស្ថាន)។

**រាជធានីភ្នំពេញ:** ភោជនីយដ្ឋាន ម្លប់ស្វាយធំ មិត្តភាព សាមគ្គី វ៉ាស៊ីនតោន ម្លប់ស្វាយត្រជាក់ចិត្ត បឹងមាស

**ខេត្តកណ្តាល:** ភោជនីយដ្ឋាន សួនម្លប់ស្នេហ៍ វិលវិញ ម្លប់ក្រខុប ។ខារ៉ាអូខេ: ត្រជាក់ចិត្តថ្មី

**កំពង់ឆ្នាំង:** ភោជនីយដ្ឋាន ភ្នំទំនើប ទួលច័ន្ទ ។ខារ៉ាអូខេ ៩៨ ៣៣៣ ១៦៨ ហង្សមាស ហោងហោង ពេញវង់ ត្រពាំងឫស្សី (សរុប ៩ក្នុងចំណោម៤៣គ្រឹះស្ថាន)

**ខេត្តប៉ៃលិន:** ភោជនីយដ្ឋាន៩៩៩ ស្រីនិច សួនមនោរម្យ ពេញចិត្ត។ខារ៉ាអូខេ រក្សាសុខ ប៉ាហ៊ុ០៦ ។ផ្ទែកឯកជន កាស៊ីណូម្កុដត្បូង កាស៊ីណូខាសឺ កាស៊ីណូប៉ៃលិន ផ្កាមមីងហ្គូ កាស៊ីណូ K-R (សរុប ១១ក្នុងចំណោម ៣៥គ្រឹះស្ថាន)

ក្នុងឆ្នាំ២០១១ មជ្ឍមណ្ឌលជាតិប្រយុទ្ធនិងជំងឺអេដស៍ សើរស្បែក និងកាមរោគបានរៀបចំការបណ្តុះបណ្តាលនិងរៀបចំកិច្ចប្រជុំថ្នាក់តំបន់ ក្នុងត្រីមាសទី១ ដែលមានការចូលរួមពី CWPD កំពង់ឆ្នាំង កំពង់ស្ពឺ សៀមរាប និងបាត់ដំបង ក្នុងខេត្តតាកែវនាថ្ងៃ ៧ ខែ ធ្នូ ឆ្នាំ២០១០។ក្នុងខេត្តកំពង់ស្ពឺ មានការចូលរួមពី CWPDប៉ៃលិន ភ្នំពេញ កណ្តាល នា ថ្ងៃ 20-22 ខែ ធ្នូ ឆ្នាំ២០១០ ក្នុងខេត្តសៀមរាបនថ្ងៃ ២៨ដល់៣០ខែធ្នូឆ្នាំ២០១០។

b. ភាពជាដៃគូសហគមន៍ នារាជធានីភ្នំពេញ

ក្នុងឆ្នាំ២០១១ ភាពជាដៃគូសហគមន៍ ធ្វើការលើក្រុម MARPs ក្នុងភ្នំពេញ។គណកម្មាការអេដស៍រាជធានីភ្នំពេញសហការណ៍ជាមួយCWPD រៀបចំកិច្ចប្រជុំក្រុមការងារបង្ការ ថែទាំ និងព្យាបាលបន្ត(CoPCT) ក្នុងខណ្ឌទួលគោក(មានអ្នកចូលរួម ៦៤នាក់នាថ្ងៃ១៦ថសីហា ២០១១) ខណ្ឌឫស្សីកែវនាថ្ងៃ១៥ កញ្ញា ២០១១(អ្នកចូលរួម៥៨នាក់) ។

រូបភាពទី 09: សកម្មភាពប្រជុំជាមួយនគរបាលអំពីគំរោងសកម្មភាពអប់រំអ្នកប្រើគ្រឿងញៀន (ភ្នំពេញ)



CWPD មានរៀបចំព្រឹត្តការណ៍ថ្នាក់ជាតិ មានទិវាអេដស៍ពិភពលោក បុណ្យនៃក្តីស្រលាញ់ និងទិវានារីអន្តរជាតិ និង ព្រឹត្តិការណ៍ពិសេសដើម្បីលើកតំកើងការទៅទទួលសេវាសុខភាព។ លទ្ធផលជាមធ្យមមានស្ត្រីចំនួន ២៨៩នាក់ ទៅ៨៦៣នាក់ ដោយរាប់បញ្ចូលសមាជិកក្លឹបចំនួនពី ២៨៣នាក់ ទៅ ៥៦៨នាក់ បានទៅទទួលសេវាសុខភាព។ ព្រឹត្តិការណ៍ពិសេសមានការគាំទ្រពីសំណាក់ម្ចាស់គ្រឹះស្ថាន អាជ្ញាធរ និងស្ត្រីផ្ទាល់ សំរាប់ជាចលករក្នុងការបង្កើនចំនួនស្ត្រីទៅទទួលសេវា។

## *យុទ្ធសាស្ត្រទី ៤: កសាងសមត្ថភាពដល់បុគ្គលិកភ្នាក់ងារអនុវត្តន៍គំរោងដៃគូ និងអ្នកពាក់ព័ន្ធក្នុងការធ្វើផែនទី អនុវត្តការងារ ការគ្រប់គ្រង និងតាមដានពិនិត្យកម្មវិធី។*

### a. ការកសាងសមត្ថភាព

CWPD បានអញ្ជើញ បុគ្គលិក ២៨ នាក់ អ្នកស្ម័គ្រចិត្ត ២៤នាក់ និងប្រធានក្រុមស្មាតហ្វើល ៣៨នាក់ ចូលរួមក្នុងវគ្គបណ្តុះបណ្តាលចំនួន ៣ថ្ងៃដែលឧបត្ថម្ភដោយ អង្គការ FHI 360 អំពីប្រធានបទនៃការអប់រំ សំរាប់កម្មវិធីបង្រៀនប្រចាំត្រីមាស។ តាមរយៈយុទ្ធសាស្ត្របង្កើនសមត្ថភាពគឺដើម្បីកសាងនូវការប្រកួតប្រជែងរបស់ស្ត្រីក្នុងការចូលរួមជាសំលេងក្នុងសហគមន៍ក្រុមងាយរងគ្រោះក្នុងប្រទេសកម្ពុជា។ ប្រធានក្រុមស្មាតហ្វើលអាចប្រមូលព័តមាននិងរបាយការណ៍ជាមួយនិងការដាក់ពាក្យធ្វើការនៅអង្គការផ្សេងទៀត។

 

រូបភាពទី១០, ១១ សកម្មភាពវគ្គបណ្តុះបណ្តាលស្មាតហ្គើលនាថ្ងៃទី១៣ដល់១៥ កញ្ញា ២០១១នៅណាហ្គាវើល

អង្គការFHI 360 បានបង្កើតវគ្គបណ្តុះបណ្តាលគ្រូបង្គោលដែលក្នុងនោះមានបុគ្គលិក CWPD ចំនួន៦រូបបានក្លាយជាគ្រូបង្គោល បន្តវគ្គបណ្តុះបណ្តាលទៅលើកក្រោយទៀត។ អង្គការ FHI 360 បានបង្កើតវគ្គបណ្តុះបណ្តាល តាមដាននិងវាយតំលៃ (M&E)ដែលមានបុគ្គលិកCWPD ចំនួន៨នាក់ បានចូលរួមនិងបន្តរៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស និងការគ្រប់គ្រងទិន្នន័យក្នុងប្រព័ន្ធទិន្នន័យ (FHICAMIS)។

**b. កិច្ចប្រជុំ**

CWPD បានរៀបចំការប្រជុំបុគ្គលិកនិងអ្នកស្ម័គ្រចិត្ត ជាទៀងទាត់ ដើម្បីបែងចែកផែនការ ការងារ ពិភាក្សាលើបញ្ហា ធ្វើការ បង្កើនសមត្ថភាពបុគ្គលិក ចំពោះការប្រជុំប្រចាំសប្តាហ៍បានធ្វើអោយមានការសំរេចចិត្តទាន់ពេលពីសំណាក់អ្នកសំរបសំរួលប្រចាំខេត្ត កែសំរួលផែនការ ផ្តល់កាបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិក និង ប្រធានក្រុមស្មាតហ្គើល។ ការប្រជុំក្រុមដឹកនាំ ត្រូវបានធ្វើជារៀងរាល់សប្តាហ៍ដើម្បីពិតនិត្យសកម្មភាព ក៏ដូចជាលទ្ធផលដែលបានកំនត់ក្នុងផែនការ។

**c. ការតាមដានវាយតម្លៃ**

ការិយាល័យកណ្តាល CWPD ធ្វើការតាមដានជាទៀងទាត់ ទៅតាមការិយាល័យថ្នាក់ខេត្ត តាមត្រីមាស ហើយអ្នកសំរបសំរួល ថ្នាក់ខេត្តចុះអភិបាលជាទៀងទាត់។ ចំពោះអង្គការ FHI360 ចុះអភិបាលយ៉ាងហោចណាស់ក៏ម្តងដែរក្នុងមួយឆ្នាំ ដើម្បីភាពជឿជាក់លើគុណភាពនៃទិន្នន័យ និង ភាពស៊ីគ្នានៃទិន្នន័យ។ មន្ត្រីតាមដាន និងវាយតំលៃប្រើប្រាស់ អនុសាសន៍ពី FHI 360 សំរាប់ជាជំនួយដល់ការតាមដាននូវដំនើរការអនុវត្តគំរោងទាំងមូល។

**B. ចំនុចជោគជ័យ និង វិសាលភាពកម្មវិធី**

**a. ចំនុចជាមោទនភាពរបស់កម្មវិធីស្មាតហ្គើល**

ក្នុងឆ្នាំ២០១១ ៦៩% នៃស្រ្តីធ្វើការសេវាកំសាន្ត បានទៅទទួលសេវានូវគ្លីនិករដ្ឋ ។កម្មវិធីស្មាតហ្គើល នូវតែនាំមុខគេក្នុងប្រព័ន្ធនៃការបញ្ជូន ទៅទទួលសេវាសុខភាពក្នុងចំណោមអង្គការដែលធ្វើការជាមួយ ស្រ្តីធ្វើការក្នុងសេវាកំសាន្ត ក្នុងប្រទេសកម្ពុជា នេះបង្ហាញអំពីសិទ្ធិរបស់ស្រ្តីក្នុងការទៅទទួលសេវាទាំងគ្លីនិករដ្ឋនិង អង្គការ ដែលត្រូវនិងគោលការណ៍ សិទ្ធិរបស់អតិថិជនក្នុងការជ្រើសរើសប្រភពសេវា។

ប្រព័ន្ធត្រួតពិនិត្យ ទិន្នន័យ និងតារាងបញ្ជូន ម៉ាស្ទ័រលើស ក្នុងកម្មវិធីស្មាតហ្គើល ជាមួយនិងការប្រើប្រាស់លេខកូដសំរាប់ អ្នកដែលជាសមាជិកស្មាតហ្គើល កំពុងដំណើរការទៅមុខសំរាប់ការកំនត់លេខអត្តសញ្ញាណដល់ស្ត្រី។ប្រព័ន្ធនេះសាមញ្ញ ឯកជនភាព សំរាប់ធ្វើអោយមានភាពងាយស្រួលលើការចងចាំអត្តសញ្ញាណបុគ្គល។លទ្ធផលអាចវាស់វែងបានតាមរយៈប្រព័ន្ធនេះផងដែរ។

កម្មវិធីស្មាតហ្គើលកំពុងតែត្រូវបានលើកទឹកចិត្តដោយ អាជ្ញាធរជាតិប្រយុទ្ធនិងជំងឺអេដសដ៍សំរាប់ការចូលរួមក្នុងការពង្រឹងភាពជាដៃគូសហគមន៍។ កម្មវិធីនេះត្រូវបានធ្វើវិមជ្ឈិការដល់ថ្នាក់ខណ្ឌក្នុងការដឹកនាំ ការអនុវត្ត ការបង្ការ ថៃទាំ និងព្យាបាលបន្តដល់ សហគមន៍ តួនាទី ការទទួលខុសត្រូវ និងការអនុវត្តនៃសុខភាពបន្តពូជ។

**b. Constraints:វិសាលភាពកម្មវិធី**

ប្រព័ន្ធនៃការអប់រំ មិនអាចគ្របដណ្តប់រាល់ស្ត្រីធ្វើការសេវាកំសាន្តក្នុងគ្រប់គ្រឹះស្ថានបានទេព្រោះកាលវិភាគធ្វើការរបស់ស្ត្រីក្នុងខែនីមួយៗ។ ជាទូទៅក្នុងការចុះអប់រំម្តងៗមិនអាចមានស្ត្រីថ្មី ២០ នាក់ទេ។ ក្នុងហាងខារ៉ាអូខេ ស្ត្រីចាប់អារម្មណ៍លើភ្ញៀវជាជាងវគ្គអប់រំនិងកាតសមាជិក។

ប្រព័ន្ធនៃការគិតប្រាក់អោយស្ត្រីពីសំណាក់ម្ចាស់សេវាមានជាប្រាក់ធិប រឺប្រាក់ខែ។ចំពោះស្ត្រីដែលទទួលបានប្រាក់ពីសំណាក់លុយធិប(មិនមានប្រាក់ខែ)ពិបាកដល់បុគ្គលិកក្នុងការគ្រប់គ្រងលេខកូដសមាជិកនិងធ្វើផែនទី។ពួកគាត់ចាប់ផ្តើមក្លាយខ្លួនជា ស្ត្រីឯករាជ្យផ្លាស់ប្តូរទីលំនៅពីកន្លែងមួយទៅកន្លែងមួយ ធ្វើការនាពេលយប់ជ្រៅ។ CWPD កំពង់ស្ពឺ កណ្តាល បានរាយការណ៍ថាចំនួនស្ត្រី ទៅទទួលសេវានៅគ្លីនិករដ្ឋមានការថយចុះ នៅពេលស្ត្រីចាប់ផ្តើមទទួលបានប្រាក់ពីសំណាក់ប្រាក់ធិប(មិនមានប្រាក់ខែ) ។

CWPD សៀមរាប បាត់ដំបង បានរាយការណ៍ថាទាំងគ្លីនិករដ្ឋ និងរ៉ាក់ មានសំភារះសំរាប់ធ្វើតេស្តVCCT និងថ្នាំមួយចំនួនសំរាប់ជំងឺកាមរោគ។

របាយការណ៍ជាលក្ខណៈបរិយាយពីសំណាក់បុគ្គលិកនៅមានកំរិតនៅឡើយ។ ភាគច្រើននៃបុគ្គលិកនៅត្រូវការ ការបណ្តុះបណ្តាលរបៀបសរសេរបាយការណ៍។ ទាំងរបាយការណ៍ប្រចាំខែនិង ប្រចាំឆ្នាំ នៅបាត់ព័តមានសំខាន់ៗ ដោយមិនបានបញ្ចូលនូវរាល់អ្វីដែលបានធ្វើទាំងអស់ (ពូកែខាងធ្វើ ប៉ុន្តែមិនពូកែខាងរាយការណ៍) ។

## C. ការគ្រប់គ្រងកម្មវិធី Program Management

### បុគ្គលិក និងអ្នកស្ម័គ្រចិត្តគំរោង

| No | Name | Sex | Job Title | Length of Employment Project | % of Time working on Project |
|---|---|---|---|---|---|
| **A-Support Staff** | | | | | |
| 1 | Meach Sotheary | F | Deputy Director | 12 years | 55% |
| 2 | Uch Ponh | F | Project Manager | 11 years | 85% |
| 3 | Chhorn Ann | M | Project Manager | 3 year | 85% |
| 4 | Ueng Vanly | F | Finance officer | 12 years | 80% |
| 5 | Soum Sen | M | Admin Officer | 12 years | 80% |
| 6 | Dy Ban | M | Driver | 12 years | 100% |
| 7 | Ke Chanarith | M | Guard | 06 years | 100% |
| 8 | Chum Sokunthear | F | Cleaner | 03 years | 100% |
| 9 | Tuy Sereyrat | F | Finance assistant | 01 year | 100% |

| | | | | | |
|---|---|---|---|---|---|
| 10 | Heng Tola | M | M&E officer | 03 months | 100% |
| **B-Project Staff** | | | | | |
| 1 | Ieng Sopheak | F | Assistant -PHP-CS | 11 years | 100% |
| 2 | Suorn Chandara | F | OW-PHP-CS | 02 years | 100% |
| 3 | Sea Saoyoury | M | OW-PHP-CS | 02 years | 100% |
| 4 | Ban Chy | M | Coordinator-PHP | 03 years | 100% |
| 5 | Khuon Phalla | F | OW-PHP | 03 years | 100% |
| 6 | Chhay Phea | M | OW-PHP-YTM | 01 year | 100% |
| 7 | Sos Afiny | F | OW-PHP | 02 yeas | 100% |
| 8 | Bo Raksa | F | Counselor-PHP | 02 years | 100% |
| 9 | Keo Sarim | F | Coordinator-KPS | 10 years | 100% |
| 10 | Suos Chantha | F | OW-KPS | 06 years | 100% |
| 11 | Eng Puthea | M | OW-KPS | 03 years | 100% |
| 12 | Chhour Kimhong | F | OW-KPCHH | 10 years | 100% |
| 13 | Chhuor Seihakneary | F | Coordinator-KPCHH | 04 years | 100% |
| 14 | Det Sokunleakhena | F | OW-KPCHH | 02 months | 100% |
| 15 | Phan Sunbopha | F | Coordinator-BTB | 09 years | 100% |
| 16 | Khem Mano | F | Ass. Coordinator-BTB | 03 years | 100% |
| 17 | Vorn Kunthea | F | OW-BTB | 02 years | 100% |
| 18 | Morn Sary | F | OW-BTB | 01 year | 100% |
| 19 | Sorn Rachana | F | OW-BTB | 02 years | 100% |
| 20 | In Sothearoth | M | Coordinator-SRP | 04 years | 100% |
| 21 | Kong Sophak | F | OW-SRP | 04 years | 100% |
| 22 | Yean Theary | F | OW-SRP | 02 years | 100% |
| 23 | Keth Simon | F | OW-SRP | 04 years | 100% |
| 24 | Soun Sopheap | M | Assist.-SRP | 03 years | 100% |
| 25 | Oep Im | M | OW-SRP-YTM | 03 years | 100% |
| 26 | Chea Leap | F | Coordinator-PLN | 09 years | 100% |
| 27 | Meas Somneang | F | OW-PLN | 08 years | 100% |
| 28 | Pat Sopheap | F | OW-PLN | 06 years | 100% |
| 29 | Sao Sophorn | F | OW-PLN | 04 years | 100% |
| 30 | Mom Sokha | F | OW-PLN | 03 year | 100% |
| 31 | Sao Chinda | F | Coordinator-KDL | 06 years | 100% |
| 32 | Nguon Sokhon | F | OW-KDL | 12 years | 100% |
| 33 | Kho Bunchouen | M | OW-KDL | 01 year | 100% |
| 34 | Sou Sanim | M | OW-PHP | 04 years | 100% |

| | | | | | |
|---|---|---|---|---|---|
| **C-SMARTgirl Leaders Engaged Part-Time** | | | | | |
| 1 | Lonh Srey Mao | F | SGL-PNP | 08 months | Part-time |
| 2 | Veang Vyna | F | SGL-PNP | 07 years | Part-time |
| 3 | Phath Srey Toch | F | SGL-PNP | 05 years | Part-time |
| 4 | Srol Srey Vourch | F | SGL-PNP | 05 years | Part-time |
| 5 | Cheam Chan Lyna | F | SGL-PNP | 01 year | Part-time |
| 6 | Nourn Chanthou | F | SGL-PNP | 02 years | Part-time |
| 7 | Un Samach | F | SGL-PNP | 03 years | Part-time |
| 8 | Ven Sonary | F | SGL-PNP | 01 year | Part-time |
| 9 | Hean Vanna | M | CF-PNP | 10 months | Part-time |
| 10 | Lay Sina | F | CF-PNP | 10 months | Part-time |
| 11 | Phorn Noupisey | F | CF-PNP | 10 months | Part-time |
| 12 | Chhorn Neang Nith | F | CF-PNP | 10 months | Part-time |
| 13 | Thoeun Bunaka | F | CF-PNP | 10 months | Part-time |
| 14 | Mao Sokhom Monika | F | CF-PNP | 01 year | Part-time |
| 15 | Veing Srey Inn | F | PF-YTM-PNP | 02 years | Part-time |
| 16 | Sin Sokna | F | PF-YTM-PNP | 10 months | Part-time |
| 17 | Sin Sok Hourth | M | PF-YTM-PNP | 04 years | Part-time |
| 18 | Veang Srey Inc | F | PF-YTM-PNP | 01 year | Part-time |
| 19 | Torn Srey Phea | F | PF-YTM-PNP | 05 months | Part-time |
| 20 | Noun Chanthou | F | PF-DU/IDU-PNP | 10 months | Part-time |
| 21 | Lun Dany | F | PF-DU/IDU-PNP | 10 months | Part-time |

| | | | | | |
|---|---|---|---|---|---|
| 22 | Tit Sophea | F | PF-DU/IDU-PNP | 10 months | Part-time |
| 23 | Lang Sreyny | F | PF-DU/IDU-PNP | 10 months | Part-time |
| 24 | Heang Chan Sopheap | F | PF-DU/IDU-PNP | 02 years | Part-time |
| 25 | Von Vy | F | SGL-BTB | 06 years | Part-time |
| 26 | Yem Kemchan Thyda | F | SGL-BTB | 06 years | Part-time |
| 27 | San Sopheap | F | SGL-BTB | 03 years | Part-time |
| 28 | Pich Pearum | F | SGL-BTB | 02 years | Part-time |
| 29 | Ann Sophea Marina | F | SGL-BTB | 03 years | Part-time |
| 30 | Thou Lina | F | SGL-BTB | 02 years | Part-time |
| 31 | VathVan Kaliyan | F | SGL-BTB | 01 year | Part-time |
| 32 | Chhon Ruby | F | SGL-BTB | 06 months | Part-time |
| 33 | Sin SoksreyPech | F | SGL-BTB | 04 Months | Part-time |
| 34 | Chhan Channy | F | SGL-BTB | 05 Months | Part-time |
| 35 | Son Sry Poa | F | SGL-DU-BTB | 04 months | Part-time |
| 36 | Prom Sidara | F | PF-YTM-BTB | 03 years | Part-time |
| 37 | Chhet Sophea | F | PF-YTM-BTB | 03 years | Part-time |
| 38 | Hong Chariya | F | PF-YTM-BTB | 01 year | Part-time |
| 39 | Meas Rotha | F | PF-YTM-SRP | 06 years | Part-time |
| 40 | Say Heang | M | PF-YTM-SRP | 02 years | Part-time |
| 41 | Phort Sopheak | M | PF-YTM-SRP | 01 year | Part-time |
| 42 | Eang Srey Van | F | SGL-SRP | 01 year | Part-time |
| 43 | Phan Vanny | F | SGL-SRP | 09 months | Part-time |
| 44 | Khut Sokhon | F | SGL-SRP | 03 years | Part-time |
| 45 | Rum Lyma | F | SGL-SRP | 01 year | Part-time |
| 46 | Som Srey Ny | F | SGL-SRP | 04 years | Part-time |
| 47 | Chum Anath | F | SGL-SRP | 2.5 years | Part-time |
| 48 | Hun Sokeun | F | SGL-SRP | 01 year | Part-time |
| 49 | Heng Sreyly | F | SGL-SRP | 05 months | Part-time |
| 50 | Khav Bona | F | SGL-SRP | 05 months | Part-time |
| 51 | Lieng Sivlang | F | SGL-SRP | 01 year | Part-time |
| 52 | Meas Chakriya | F | SGL-SRP | 01 year | Part-time |
| 53 | Ne Sokthon | F | SGL-SRP | 08 months | Part-time |
| 54 | Sin Sreypoch | F | SGL-DU-SRP | 01 year | Part-time |
| 55 | Lay Kaliyan | F | SGL-KD | 1.5 years | Part-time |
| 56 | Vann Daliss | F | SGL-KD | 08 months | Part-time |
| 57 | Ouk Somalay | F | SGL-KD | 05 years | Part-time |
| 58 | Keo Sopha | F | SGL-KD | 02 years | Part-time |
| 59 | Sok Sreymy | F | SGL-KPCHH | 03 years | Part-time |
| 60 | Um Soklen | F | SGL-KPCHH | 03 years | Part-time |
| 61 | Boung Srey Sor | F | SGL-KPCHH | 03 months | Part-time |
| 62 | Meas Sok Ry | F | SGL-KPS | 02 years | Part-time |
| 63 | Korn Sok Chea | F | SGL-KPS | 06 years | Part-time |
| 64 | Lim Sothary | F | SGL-KPS | 01 year | Part-time |
| 65 | Phan Srey Ny | F | SGL-PL | 03 year | Part-time |
| 66 | Pong Sokny | F | SGL-PL | 02 years | Part-time |
| 67 | Soy Srey Mom | F | SGL-PL | 02 years | Part-time |
| 68 | Moa Maraty | F | SGL-PL | 03 yeas | Part-time |
| 69 | Ren Soknvy | F | SGL-PL | 1.5 yeas | Part-time |
| 70 | Lounh Srey Mao | F | SGL-PL | 1.5 yeas | Part-time |
| 71 | Heak Chansopheap | F | SGL-PL | 3 years | Part-time |
| 72 | Torn Sokhoeun | F | SGL-PL | 1 year | Part-time |
| 73 | Huon Sreymo | F | SGL-PL | 01 month | Part-time |
| 74 | Hok KimHen | F | SGL-PL | 10 month | Part-time |
| 75 | Nuon Sopheak | F | SGL-PL | 10 month | Part-time |
| 76 | Meas Kolap | F | CF-PL | 01 year | Part-time |
| 77 | Leng Nalat | M | CF-PL | 10 months | Part-time |
| 78 | Va Sunly | F | CF-PL | 10 months | Part-time |
| 79 | Sem Sokhon | M | CF-PL | 03 months | Part-time |
| 80 | Mao Maraty | F | CF-PL | 03 years | Part-time |
| 81 | Thoeun Sokheng | F | CF-PL | 01 years | Part-time |

| | | | | | |
|---|---|---|---|---|---|
| 82 | Leng Nalath | F | CF-PL | 01 years | Part-time |
| 83 | Sin Sokhan | F | CF-PL | 01 years | Part-time |
| 84 | Kanha | F | CF-PL | 07 month | Part-time |
| 85 | Mey Maravan | F | CF-PL | 07 month | Part-time |
| 86 | Sourn Thida | F | CF-PL | 06 month | Part-time |

## IV. ជំហានបន្ទាប់

ថ្វីបើ CWPD,ទទួលបានជោគជ័យនៃការអនុវត្តគំរោង ការពារនិងបង្ការ មេរោគអេដស៍ ក៏ប៉ុន្តែយើងនៅតែមានកង្វល់អំពីរលកទីពីរនៃមេរោគ អេដស៍ ក្នុងប្រទេសកម្ពុជា។ CWPD ជឿជាក់ថា កម្មវិធីស្មាតហ្គើលនិងបន្តតួនាទីវិជ្ជមាន និងយ៉ាងមានប្រសិទ្ធិភាពក្នុងការ ការពារនិងបង្ការ មេរោគអេដស៍ ក្នុងចំណោមស្ត្រីធ្វើការសេវាកំសាន្ត។

សំរាប់ជំងឺអេដស៍និងកាមរោគ ការប្រើប្រាស់ស្រោមអនាម័យក្នុងកំលុងពេលរួមភេទជាវិធីសាស្រ្តដ៏មានប្រសិទ្ធិភាពសំរាប់ ស្ត្រីធ្វើការសេវាកំសាន្ត ក្នុងការបញ្ចៀសនូវជំងឺ អេដស៍និងកាមរោគ។ការប្រើស្រោមអនាម័យ១០០ភាគរយ នៅតែជាសារចំបង។

សំរាប់ការពន្យារកំនើតដោយប្រើប្រាស់ស្រោមអនាម័យជាមួយដៃគូនៅពុំទាន់ឥតខ្ចោះនៅឡើយ ពួកគេប្រហែលជាត្រូវការនូវជំរើសទី២ ប្រសើរ និងគួរទុកចិត្តជាង ការប្រើស្រោមអនាម័យ

ថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១១

អ្នកគ្រប់គ្រងគំរោង